# ANTI-CORRUPTION UNDERTAKINGS

## DEFINITIONS

**"Public Official"** means an elected or appointed official, employee or agent of any national, regional or local government/state or department, agency or instrumentality of any such government/state or any enterprise in which such a government/state owns, directly or indirectly, a majority or controlling interest; an official of a political party; a candidate for public office; and any official, employee or agent of any public international organization.

**"Close Family Member of a Public Official"** means a husband/spouse or partner, one of his/her children, siblings or parents; the husband/spouse or partner of his/her children or siblings; or any household member.

## PREVENTION OF CORRUPTION

In recognition of the principles enshrined in the pertinent international and regional conventions on combating corruption and to ensure compliance with the anti-corruption laws applicable to the activities under the Contract and any other anti-corruption laws otherwise applicable to the Parties or their ultimate parent company:

**1-** The Supplier, in respect of the Contract and the matters that are the subject of the Contract, warrants that neither it nor to its knowledge anyone on its behalf, has made or offered nor will make or offer any payment, gift, or promise or give any advantage, whether directly or through an intermediary, to or for the use of any Public Official, where such payment, gift, promise or advantage would be for purposes of:

(i) Influencing any act or decision of such Public Official;

(ii) Inducing such Public Official to do or omit to do any act in violation of his or her lawful duties;

(iii) Securing any improper advantage; or

(iv)Inducing such Public Official to use his or her influence to affect any act or decision of any department, agency or instrumentality of any government or public enterprise.

**2 -** The Supplier, in respect of the Contract and the matters that are the subject of the Contract, warrants that it has not made or offered and will not make or offer any payment, gift, or promise or give any advantage, whether directly or through intermediaries, to or for the use of any person (other than a Public Official) insofar as such payment, gift, promise or advantage would be for purposes of inducing such person to do or omit to do any act in violation of his or her lawful duty or to secure any improper advantage, or otherwise to do or refrain from doing something that would violate the laws applicable to the activities under the Contract.

**3 -** The Supplier shall cause Supplier's personnel and subcontractors to comply with the obligations set forth in this Attachment and to warrant the same under the terms of their agreements with any Subcontractors. In particular, the Supplier shall perform compliance due diligences on all major Subcontractors in order to ensure that they shall act in strict compliance with the anti-corruption laws applicable, conducting appropriate investigations. The Buyer reserves the right to request proof of and/or documentation relating to such due diligences.

**4 -** All financial settlements, billings and reports rendered to the Buyer shall accurately and in reasonable detail reflect all activities and transactions undertaken in the performance of the Contract. The Supplier also shall maintain adequate internal controls to ensure that all payments made in performance of the Contract are authorized and in compliance with the Contract. The Buyer reserves the right to perform itself or through a duly authorized representative, audits at Supplier's premises of all payments made by or on behalf of the Supplier for Work and/or Services performed under the Contract. The Supplier agrees to cooperate fully in any such audit, including by making the relevant books and records available to the Buyer or its duly authorized representative and by answering any relevant questions that the Buyer may have relating to the Supplier's performance under this Contract.

**5 -** All payments by the Buyer to the Supplier shall be made in accordance with the terms of payment specified in the Contract. The payment indications notified in the Service Provider's invoices shall be deemed to constitute a representation and

# ការកិច្ចប្រឆាំងអំពើពុករលួយ

## និយមន័យ

**"មន្ត្រីសាធារណៈ"** មានន័យថា មន្ត្រី និយោជិត ឬភ្នាក់ងារដែលត្រូវបានជ្រើសរើស ឬតែងតាំងរបស់រដ្ឋាភិបាល/រដ្ឋថ្នាក់ជាតិ ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋាន ឬនាយកដ្ឋាន ទីភ្នាក់ងារ ឬអង្គភាពនៃរដ្ឋាភិបាល/រដ្ឋនោះ ឬសហគ្រាសណាមួយដែលក្នុងនោះរដ្ឋាភិបាល/រដ្ឋបែបនោះកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោល នូវផលប្រយោជន៍ភាគច្រើន ឬផលប្រយោជន៍គ្រប់គ្រង មន្ត្រីនៃគណបក្សនយោបាយណាមួយ បេក្ខជនសម្រាប់មុខតំណែងសាធារណៈ និងមន្ត្រី និយោជិត ឬភ្នាក់ងារណាមួយរបស់អង្គការអន្តរជាតិសាធារណៈណាមួយ។

**"សមាជិកគ្រួសារជិតដិតនៃមន្ត្រីសាធារណៈ"** មានន័យថា ស្វាមី/សហព័ទ្ធ ឬដៃគូ អ្នកណាម្នាក់ក្នុងចំណោមកូន បងប្អូនបង្កើត ឬឪពុកម្ដាយរបស់ខ្លួន ស្វាមី/សហព័ទ្ធ ឬដៃគូរបស់កូន ឬបងប្អូនបង្កើតរបស់ខ្លួន ឬសមាជិកគ្រួសារណាម្នាក់។

## ការទប់ស្កាត់អំពើពុករលួយ

ដើម្បីទទួលស្គាល់គោលការណ៍ដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិ និងតំបន់ដែលពាក់ព័ន្ធ ទាក់ទងនឹងការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងដើម្បីធានានូវអនុលោមភាពតាមច្បាប់ប្រឆាំងអំពើពុករលួយ ពាក់ព័ន្ធនឹងសកម្មភាព ក្រោមកិច្ចសន្យា និងច្បាប់ប្រឆាំងអំពើពុករលួយផ្សេងទៀតដែលអនុវត្តចំពោះគូភាគី ឬក្រុមហ៊ុនមេចុងក្រោយរបស់ពួកគេ៖

**១-** អ្នកផ្គត់ផ្គង់ទាក់ទងនឹងកិច្ចសន្យានេះ និងបញ្ហាទាំងឡាយដែលជាកម្មវត្ថុនៃកិច្ចសន្យា ធានាថា ខ្លួន ឬអ្នកណាម្នាក់តាងនាមឲ្យខ្លួន តាមដែលខ្លួនដឹង មិនបានធ្វើឬផ្តល់ ហើយនឹងមិនធ្វើឬផ្តល់ការបង់ប្រាក់ អំណោយណាមួយ ឬសន្យា ឬផ្តល់អត្ថប្រយោជន៍ណាមួយ ទោះដោយផ្ទាល់ក្តី ឬតាមរយៈអន្តរការីក្តី ដល់ ឬសម្រាប់ការប្រើប្រាស់របស់មន្ត្រីសាធារណៈណាមួយឡើយ ដែលការបង់ប្រាក់ អំណោយ ការសន្យា ឬអត្ថប្រយោជន៍បែបនោះ គឺដើម្បីគោលបំណង៖

(i) ជះឥទ្ធិពលលើសកម្មភាព ឬសេចក្តីសម្រេចណាមួយរបស់មន្ត្រីសាធារណៈរូបនោះ

(ii) ជំរុញឲ្យមន្ត្រីសាធារណៈរូបនោះធ្វើ ឬមិនធ្វើសកម្មភាពណាមួយ ដោយបំពានលើករណីយកិច្ចស្របច្បាប់របស់ខ្លួន

(iii) ធានានូវអត្ថប្រយោជន៍មិនសមស្របណាមួយ ឬ

(iv) ជំរុញមន្ត្រីសាធារណៈរូបនោះឲ្យប្រើប្រាស់ឥទ្ធិពលរបស់ខ្លួន ដើម្បីធ្វើឲ្យប៉ះពាល់ដល់សកម្មភាព ឬសេចក្តីសម្រេចរបស់នាយកដ្ឋាន ទីភ្នាក់ងារ ឬអង្គភាពណាមួយរបស់រដ្ឋាភិបាល ឬសហគ្រាសសាធារណៈណាមួយ។

**២-** អ្នកផ្គត់ផ្គង់ទាក់ទងនឹងកិច្ចសន្យានេះ និងបញ្ហាទាំងឡាយដែលជាកម្មវត្ថុនៃកិច្ចសន្យាធានាថា ខ្លួនមិនបានធ្វើ ឬផ្តល់ ហើយនឹងមិនធ្វើ ឬផ្តល់ការបង់ប្រាក់ អំណោយណាមួយ ឬសន្យា ឬផ្តល់អត្ថប្រយោជន៍ណាមួយ ទោះដោយផ្ទាល់ក្តី ឬតាមរយៈអន្តរការីក្តី ដល់ ឬសម្រាប់ការប្រើប្រាស់របស់បុគ្គលណាមួយ (ក្រៅពីមន្ត្រីសាធារណៈ) ឡើយ ក្នុងកម្រិតដែលការបង់ប្រាក់ អំណោយ ការសន្យា ឬអត្ថប្រយោជន៍បែបនោះ គឺដើម្បីគោលបំណងជំរុញឲ្យបុគ្គលនោះធ្វើ ឬមិនធ្វើទង្វើណាមួយ ដោយបំពានករណីយកិច្ចស្របច្បាប់របស់គាត់ ឬនាង ឬដើម្បីធានានូវអត្ថប្រយោជន៍មិនសមស្របណាមួយ ឬដើម្បីធ្វើ ឬមិនធ្វើអ្វីមួយដែលនឹងបំពានច្បាប់ពាក់ព័ន្ធនឹងសកម្មភាពទាំងឡាយ ក្រោមកិច្ចសន្យា។

**៣-** អ្នកផ្គត់ផ្គង់ត្រូវធ្វើឲ្យបុគ្គលិក និងអ្នកម៉ៅការរបស់ខ្លួនគោរពតាមកាតព្វកិច្ចទាំងឡាយដែលមានចែងនៅក្នុងឯកសារភ្ជាប់នេះ និងធានានូវការគោរពកាតព្វកិច្ចទាំងនេះ យោងតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងរបស់ពួកគេជាមួយអ្នកម៉ៅការបន្តណាមួយ។ ជាពិសេស អ្នកផ្គត់ផ្គង់ត្រូវអនុវត្តការប្រុងប្រយ័ត្នហ្មត់ចត់ផ្នែកអនុលោមភាពលើអ្នកម៉ៅការបន្តសំខាន់ៗទាំងអស់ ដើម្បីធានាថា ពួកគេធ្វើសកម្មភាព ដោយអនុលោមយ៉ាងខ្ជាប់ខ្ជួនតាមច្បាប់ប្រឆាំងអំពើពុករលួយដែលពាក់ព័ន្ធ ដោយធ្វើការស៊ើបអង្កេតសមស្រប។ អ្នកទិញរក្សាសិទ្ធិស្នើសុំភស្តុតាងនៃ និង/ឬឯកសារទាក់ទងនឹងការប្រុងប្រយ័ត្នហ្មត់ចត់បែបនោះ។

**៤-** រាល់របាយការណ៍ហិរញ្ញវត្ថុ វិក្កយបត្រ និងរបាយការណ៍ទាំងអស់ដែលផ្តល់ដល់អ្នកទិញ ត្រូវឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ និងយ៉ាងលម្អិតសមស្របអំពីសកម្មភាព និងប្រតិបត្តិការទាំងអស់ដែលធ្វើឡើង ក្នុងការអនុវត្តកិច្ចសន្យា។ អ្នកផ្គត់ផ្គង់ក៏ត្រូវរក្សាការត្រួតពិនិត្យផ្ទៃក្នុងឲ្យបានគ្រប់គ្រាន់ផងដែរដើម្បីធានាថា រាល់ការទូទាត់ទាំងអស់ដែលបានធ្វើឡើងនៅក្នុងការ អនុវត្តកិច្ចសន្យា ត្រូវបានអនុញ្ញាត និងអនុលោមតាមកិច្ចសន្យា។ អ្នកទិញរក្សាសិទ្ធិក្នុងការអនុវត្ត ដោយខ្លួនឯង ឬតាមរយៈតំណាងដែលមានការអនុញ្ញាតត្រឹមត្រូវនូវសវនកម្មនៅទីតាំងរបស់អ្នកផ្គត់ផ្គង់ លើការទូទាត់ទាំងអស់ដែលធ្វើឡើងដោយ ឬតាងនាមឲ្យអ្នកផ្គត់ផ្គង់ សម្រាប់ការងារ និង/ឬសេវាដែលអនុវត្តក្រោមកិច្ចសន្យានេះ។ អ្នកផ្គត់ផ្គង់យល់ព្រមសហប្រតិបត្តិការយ៉ាងពេញលេញនៅក្នុងសវនកម្មបែបនេះណាមួយ រួមទាំងតាមរយៈការធ្វើឲ្យបញ្ជី និងកំណត់ត្រាពាក់ព័ន្ធ មានសម្រាប់ អ្នកទិញ ឬតំណាងមានការអនុញ្ញាតត្រឹមត្រូវរបស់ខ្លួន និងតាមរយៈការឆ្លើយទៅនឹងសំណួរពាក់ព័ន្ធណាមួយដែលអ្នកទិញអាចមាន ទាក់ទងនឹងការអនុវត្តកាតព្វកិច្ចរបស់អ្នកផ្គត់ផ្គង់ ក្រោមកិច្ចសន្យានេះ។

**៥-** រាល់ការទូទាត់ទាំងអស់ដោយអ្នកទិញទៅកាន់អ្នកផ្គត់ផ្គង់ ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌទាំងឡាយនៃការទូទាត់ដែលបញ្ជាក់នៅក្នុងកិច្ចសន្យា។ ការបង្ហាញការទូទាត់ដែលត្រូវបានជូនដំណឹងនៅក្នុងវិក្កយបត្ររបស់អ្នកផ្តល់សេវា នឹងត្រូវចាត់ទុកថាជាការ

warranty by the Supplier that the bank account so notified is owned solely by the Supplier and that no person other than the Supplier has any ownership of or interest in such account.

**6 -** The Supplier represents and warrants that no Public Official or Close family member of a Public Official owns or possesses, directly or indirectly, shares or any other beneficial interest in the Supplier (other than through ownership of publicly traded securities that is not sufficient to constitute a controlling interest), or is a director, officer or agent of the Supplier, except for any ownership, interest or position that the Supplier has disclosed to the Buyer in writing. The foregoing representation and warranty will continue so long as this Contract remains in effect. The Supplier agrees to notify the Buyer promptly and in writing of any developments that would or might affect the accuracy of the foregoing representation or warranty. In any case, if a Public Official or Close family member of a Public Official owns or acquires, directly or indirectly, shares or any other beneficial interest in the Supplier, or is or becomes a director, officer or agent of the Supplier, the Supplier shall take appropriate steps to ensure that such Public Official or Close family member of a Public Official avoids any conflict of interest, complies with the legislation applicable in accordance with the place of performance of the Contract prohibiting conflicts of interest on the part of Public Officials and complies with the anti-corruption provisions described in this Attachment.

**6.bis -** Notwithstanding the above, the Parties accept and acknowledge that, in the event any Supplier or Subcontractor is owned in part by a State owned company or may, whether now or in the future, be considered as a governmental entity or quasi-governmental entity at law, it is possible that a Public Official may serve as a director, officer or employee of such Contractor or Subcontractor or its subsidiaries. In such event, the Parties agree that, the Contractor or such Subcontractor may have one or more directors, officers or employees who qualify as Public Officials, provided that:

(i) the Public Official is occupying such position within the Contractor or Subcontractor fully in accordance with laws that are attributable to such party and as may be required there-under;

(ii) the Public Official's appointment as a director, officer or employee of the Contractor or Subcontractor is reviewed and approved by the State owned company;

(iii) any payment to or on behalf of the Public Official is reviewed and approved by the State owned company and does not exceed the remuneration that would be reasonable for a person serving in that particular position within the Contractor or Subcontractor; and

(iv) such remuneration is fully consistent with applicable laws and the matters that are the subject of the Contract and is not made to influence any official act, decision or omission of such Public Official or reward the Public Official in respect of any of the same that may have been taken in the past.

**7 -** Without prejudice to any other rights or remedies, the Buyer otherwise shall have, hereunder or at law, including but not limited to damages for breach of the Contract, if any of the undertakings or requirements of this Attachment have not been complied with or fulfilled by the Supplier in any respect, the right:

(i) to suspend payment and/or require reimbursement of any advance payment made under the Contract, and/or

(ii) to suspend and/or terminate the Contract for Supplier's default with immediate effect.

For the Supplier

________________________________

Signature, name, date and company stamp

អះអាង និងការធានាដោយអ្នកផ្គត់ផ្គង់ថា គណនីធនាគារដែលត្រូវបានជូនដំណឹងបែបនោះ គឺជាកម្មសិទ្ធិទាំងស្រុងរបស់អ្នកផ្គត់ផ្គង់ និងថា ពុំមានបុគ្គលណាក្រៅពីអ្នកផ្គត់ផ្គង់ មានកម្មសិទ្ធិលើ ឬផលប្រយោជន៍ណាមួយនៅក្នុងគណនីនោះឡើយ។

**៦-** អ្នកផ្គត់ផ្គង់អះអាង និងធានាថា មិនមានមន្ត្រីសាធារណៈ ឬសមាជិកគ្រួសារជិតដិតណាម្នាក់នៃមន្ត្រីសាធារណៈ មានកម្មសិទ្ធិ ឬកាន់កាប់ ដោយផ្ទាល់ ឬដោយប្រយោល នូវភាគហ៊ុន ឬសិទ្ធិលើផលកម្រៃផ្សេងទៀតណាមួយនៅក្នុងអ្នកផ្គត់ផ្គង់ (ក្រៅពីតាមរយៈកម្មសិទ្ធិលើមូលបត្រជួញដូរជាសាធារណៈដែលមិនគ្រប់គ្រាន់ដើម្បីបង្កើតជា
ផលប្រយោជន៍គ្រប់គ្រង) ឬជាអភិបាល មន្ត្រី ឬភ្នាក់ងាររបស់អ្នកផ្គត់ផ្គង់ឡើយ លើកលែងតែកម្មសិទ្ធិ ផលប្រយោជន៍ ឬមុខតំណែងណាមួយដែលអ្នកផ្គត់ផ្គង់បានលាតត្រដាងដល់អ្នកទិញជាលាយលក្ខណ៍អក្សរ។ ការអះអាង និងការធានាខាងដើម នឹងបន្ត ដរាបណាកិច្ចសន្យានេះនៅតែមានប្រសិទ្ធភាព។ អ្នកផ្គត់ផ្គង់យល់ព្រមជូនដំណឹងដល់អ្នកទិញភ្លាមៗ និងជាលាយលក្ខណ៍អក្សរអំពីការវិវឌ្ឍណាមួយដែលនឹង ឬអាចប៉ះពាល់ដល់ភាពត្រឹមត្រូវនៃការអះអាង និងការធានាខាងដើម។ ក្នុងករណីណាក៏ដោយ ប្រសិនបើមន្ត្រីសាធារណៈ ឬសមាជិកគ្រួសារជិតដិតនៃមន្ត្រីសាធារណៈ កាន់កាប់ ឬទទួលបាន ដោយផ្ទាល់ ឬដោយប្រយោល នូវភាគហ៊ុន ឬសិទ្ធិលើផលកម្រៃផ្សេងទៀតណាមួយនៅក្នុងអ្នកផ្គត់ផ្គង់ ឬគឺជា ឬក្លាយជាអភិបាល មន្ត្រី ឬភ្នាក់ងាររបស់អ្នកផ្គត់ផ្គង់ អ្នកផ្គត់ផ្គង់ត្រូវចាត់វិធានការសមស្របដើម្បីធានាថា មន្ត្រីសាធារណៈ ឬសមាជិកគ្រួសារជិតដិតរបស់មន្ត្រីសាធារណៈ ចៀសវាងនូវទំនាស់ផលប្រយោជន៍ គោរពតាមច្បាប់ពាក់ព័ន្ធ ស្របតាមទីកន្លែងអនុវត្តកិច្ចសន្យា ដែលហាមឃាត់ទំនាស់ផលប្រយោជន៍ពីសំណាក់មន្ត្រីសាធារណៈ និងគោរពតាមបញ្ញត្តិស្តីពីការប្រឆាំងអំពើពុករលួយដែលរៀប រាប់នៅក្នុងឯកសារភ្ជាប់នេះ។

**៦ស្ទួន-** ទោះបីជាមានប្រការខាងលើក៏ដោយ គូភាគីទទួលយក និងទទួលស្គាល់ថា ក្នុងករណីដែលអ្នកផ្គត់ផ្គង់ ឬអ្នកម៉ៅការបន្តណាមួយត្រូវបានកាន់កាប់មួយផ្នែកដោយក្រុមហ៊ុនជាកម្មសិទ្ធិរបស់រដ្ឋ ឬ ទោះជាបច្ចុប្បន្នក្តី ឬនៅពេលអនាគតក្តី អាចត្រូវបានចាត់ទុកថាជាអង្គភាពរដ្ឋាភិបាល ឬអង្គភាពស្រដៀងរដ្ឋាភិបាលតាមច្បាប់ វាអាចទៅរួចដែលមន្ត្រីសាធារណៈអាចបម្រើការងារជាអភិបាល មន្ត្រី ឬនិយោជិតរបស់អ្នកម៉ៅការ ឬអ្នកម៉ៅការបន្តបែបនោះ ឬក្រុមហ៊ុនសាខារបស់ខ្លួន។ ក្នុងករណីបែបនេះ គូភាគីព្រមព្រៀងថា អ្នកម៉ៅការ ឬអ្នកម៉ៅការបន្តបែបនោះអាចមានអភិបាល មន្ត្រី ឬនិយោជិតមួយ ឬច្រើនដែលមានលក្ខណៈសម្បត្តិធ្វើជាមន្ត្រីសាធារណៈ ក្នុងលក្ខខណ្ឌថា៖

(i) មន្ត្រីសាធារណៈនោះកំពុងកាន់មុខតំណែងបែបនោះនៅក្នុងអ្នកម៉ៅការ ឬអ្នកម៉ៅការបន្ត ដោយស្រប តាមច្បាប់ទាំងស្រុង ដែលបណ្តាលមកពីភាគីនោះ និងអាចត្រូវបានតម្រូវ ក្រោមច្បាប់នោះ

(ii) ការតែងតាំងមន្ត្រីសាធារណៈជាអភិបាល មន្ត្រី ឬនិយោជិតរបស់អ្នកម៉ៅការ ឬអ្នកម៉ៅការបន្ត ត្រូវបានពិនិត្យ និងឯកភាពដោយក្រុមហ៊ុនជាកម្មសិទ្ធិរបស់រដ្ឋ

(iii) ការទូទាត់ណាមួយដល់ ឬជូសមុខឲ្យមន្ត្រីសាធារណៈ ត្រូវបានពិនិត្យ និងឯកភាពដោយក្រុមហ៊ុនជា កម្មសិទ្ធិរបស់រដ្ឋ និងមិនត្រូវលើសពីប្រាក់ឈ្នួលដែលសមស្របសម្រាប់បុគ្គលណាម្នាក់ដែលបម្រើការងារនៅក្នុងមុខតំណែងជាក់លាក់នោះ នៅក្នុងអ្នកម៉ៅការ ឬអ្នកម៉ៅការបន្តឡើយ និង

(iv) ប្រាក់ឈ្នួលនេះត្រូវស្របទាំងស្រុងតាមច្បាប់ពាក់ព័ន្ធ និងបញ្ហាទាំងឡាយដែលជាកម្មវត្ថុនៃកិច្ចសន្យា និងមិនត្រូវបានធ្វើឡើងដើម្បីជះឥទ្ធិពលដល់សកម្មភាពផ្លូវការ សេចក្តីសម្រេច ឬការមិនធ្វើសកម្មភាពណាមួយរបស់មន្ត្រីសាធារណៈនោះ ឬដើម្បីផ្តល់រង្វាន់ដល់មន្ត្រីសាធារណៈនោះ ទាក់ទងនឹងសកម្មភាពណាមួយដូចគ្នានោះ ដែលអាចត្រូវបានធ្វើឡើងនៅក្នុងអតីតកាលឡើយ។

**៧-** ដោយមិនប៉ះពាល់ដល់សិទ្ធិ ឬដំណោះស្រាយផ្សេងទៀតណាមួយ អ្នកទិញ យោងតាមឯកសារនេះ ឬតាមច្បាប់ រួមមានជាអាទិ៍ សំណងខូចខាតសម្រាប់ការរំលោភបំពានកិច្ចសន្យា ប្រសិនបើភារកិច្ច ឬលក្ខខណ្ឌតម្រូវណាមួយនៃឯកសារភ្ជាប់នេះមិនត្រូវបានគោរពតាម ឬបំពេញតាមដោយអ្នកផ្គត់ផ្គង់ ក្នុងទិដ្ឋភាពណាមួយ ត្រូវមានសិទ្ធិ៖

(i) ផ្អាកការទូទាត់ និង/ឬតម្រូវឲ្យមានការចេញសងវិញនូវប្រាក់ទូទាត់ជាមុនណាមួយដែលធ្វើឡើងក្រោមកិច្ចសន្យា និង/ឬ

(ii) ផ្អាក និង/ឬបញ្ចប់កិច្ចសន្យា ជាមួយប្រសិទ្ធភាពភ្លាមៗដោយសារកំហុសរបស់អ្នកផ្គត់ផ្គង់។

ជូសអ្នកផ្គត់ផ្គង់

________________________________

ហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងត្រាក្រុមហ៊ុន